**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីស្លាប់ស្ត្រីជនជាតិខ្មែរអាយុ ៥៦ឆ្នាំ ដោយសារស្ទះសរសៃឈាមបេះដូងភ្លាមៗ មិនមែនស្លាប់ដោយសារជំងឺកូវីដ-១៩

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា យោងតាមរបាយការណ៍ពីមន្ទីរសុខាភិបាលរាជធានីភ្នំពេញ បានឱ្យដឹងថា ស្ត្រីជនជាតិខ្មែរអាយុ ៥៦ឆ្នាំ ដែលរស់នៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ បានស្លាប់បាត់បង់ជីវិត នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១២:០០នាទីថ្ងៃត្រង់ នៅគេហដ្ឋានរបស់សព។

ស្ត្រីជនជាតិខ្មែរអាយុ ៥៦ឆ្នាំ ជាអ្នកធ្វើចត្តាឡីស័កនៅផ្ទះផ្ទាល់ខ្លួន តាំងពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ អ្នកជំងឺមានជំងឺលើសសម្ពាធឈាមប្រចាំកាយ កំពុងប្រើប្រាស់ថ្នាំជាប្រចាំ។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១១:៣០ថ្ងៃត្រង់ គាត់កំពុងពិសារបាយ ស្រាប់តែសន្លប់បាត់បង់ស្មារតីភ្លាមៗ ក្រុមគ្រួសារបានជួយសង្គ្រោះដោយធ្វើចលនាបេះដូងមួយសន្ទុះ គាត់បានស្លាប់បាត់បង់ជីវិតនៅវេលាម៉ោង ១២:០០នាទីថ្ងៃត្រង់នៅគេហដ្ឋានរបស់គាត់។

ក្រោយទទួលបានដំណឹងពីក្រុមគ្រួសារភ្លាម ក្រុមឆ្លើយតបបន្ទាន់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បានចុះទៅយកសំណាករបស់សព នៅថ្ងៃដដែលនេះលទ្ធផលបានបង្ហាញថាសពមានវិជ្ជមានវីរុសកូវីដ-១៩។

ក្រុមការងារមន្ទីរសុខាភិបាលរាជធានីភ្នំពេញ បានចាត់ចែងបូជាសពតាមវិធានសុខាភិបាល។

**ការសន្និដ្ឋានរបស់ក្រុមគ្រូពេទ្យ៖** ស្ត្រីជនជាតិខ្មែរអាយុ ៥៦ឆ្នាំ ខាងលើនេះបានស្លាប់បាត់បង់ជីវិតដោយសារស្ទះសរសៃឈាមបេះដូងភ្លាមៗ នៅលើអ្នកជំងឺមានផ្ទុកវីរុសកូវីដ-១៩ មិនមែនស្លាប់ដោយសារជំងឺកូវីដ-នោះឡើយ។

ក្រសួងសុខាភិបាល សូមចូលរួមចំណែកសោកស្តាយជាពន់ពេក និងសូមចូលរួមមរណៈទុក្ខយ៉ាងក្រៀមក្រំជាទីបំផុតជាមួយក្រុមគ្រួសារសព។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៥រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២១